# ចម្លាក់ឯកបទក្នុងសិល្បៈខ្មែរ

*Ekapada Iconography*

ចម្លាក់រូបឯកបទ គឺពុំឃើញមានឆ្លាក់ទេនៅមុនសម័យអង្គរ និងជាពិសេសពុំសូវនិយមឆ្លាក់ទេនៅតំបន់អង្គរ។ ប៉ុន្តែក្នុងរាជព្រះបាទជ័យវរ្ម័នទី៤ បង្ហាញចម្លាក់រឿងឯកបទនេះដង្កល់នៅប្រកទី២ផ្នែកខាងលិចនៅសតវត្សទី១០នៃគ.ស។ ដោយឯកបទ គឺជារឿងមួយក្នុងចំណោមរឿងមហេស្វរមុរតិទាំង២៥ ក្នុងគម្ពីសិវៈនិកាយបរមេស្វរ ឬសទាសិវៈ។ ឧទាហណ៍មួយចំនួនដូចជារឿង ឧមាមហេស្វរ ហរិហរៈ សិវៈរាំ និងសោមស្កន្ទជាដើម។ល។[៧]

ក្រោយមកទៀត យើងប្រទះឃើញមានរូបដូចគ្នាមួយទៀតនៅសារមន្ទីរជាតិភ្នំពេញដែលមកពីព្រៃជ្រូក នៅចុងសតវត្សទី១០គ.ស ដែលបន្តឆ្លាក់ក្រោយរចនាបថកោះកេរ(រូបលេខ១)។ ក្រៅពីចម្លាក់ទាំងពីនេះទៅ យើងពុំសូវឃើញមានឆ្លាក់ជារូបឯកបទដូច្នេះទៀតទេ គឺមានតែចម្លាក់បង្ហាញជារូបត្រិមុរតិតែម្តង។ ចំណែកការបង្ហាញរូបឯកបទខាងលើនេះ នៅកោះកេរ ឃើញបង្ហាញជាមួយរូបសទាសិវៈ សិវៈរាំ ឧមាមហេស្វរ និងរូបគិរតជាមួយអជ៌ុន នៅក្រុមប្រាសាទរួមកោះកេរ។ ក្រោយមកទៀតចម្លាក់នេះមាននៅតំបន់ព្រៃជ្រូក គឺបង្ហាញរូបបញ្ចូលគ្នាដែលមានព្រះភក្រ្ត៥ជាសទាសិវៈផង និងរូបឯកបទផង។ ត្រង់ចំនុចនេះ ចម្លាក់នៅតំបន់ព្រៃជ្រូក គឺបង្ហាញដូចគ្នា ទៅនឹងរូបសទាសិវៈឆ្លាក់បញ្ចូលគ្នាជាមួយសិវៈរាំ នៅប្រាសាទក្រហមដែរ (រូបលេខ២)។



**រូបលេខ១៖** រូបឯកបទ(*Ekapada*) ដើមសតវត្សទី១០នៃគ.ស នៅប្រកចូលទី២ផ្នែកខាងលិចប្រាសាទក្រហម។ (ប្រភព៖ EFEO_CAM11280)

**រូបភាពទី២៖** ចម្លាក់សទាសិវៈបញ្ចូលជាមួយទម្រង់សិវៈរាំដើមសតវត្សទី១០នៃគ.ស នៅប្រាសាទក្រហមកោះកេរ(EFEO)



[៧] Sharma, 1976: 3

រឿងឯកបទនេះសំដៅទៅលើទិដ្ឋភាពជើងម្ខាង នៃអាទិទេពព្រហ្មញ្ញសាសនា។ រឿងឯកបទ ត្រូវបានតំណាងជាចម្បង នៅក្នុងទំរង់រូបតំណាងបីផុសចេញពីជើងតែមួយ។ នៅក្នុងទម្រង់ឯកបទមុរតិ (*Ekapada-murti*) (រូបតំណាងជើងមួយ) ទ្រង់គឺ មានជើងម្ខាង និងប្រដាប់ដោយអាវុធ៤។[២] នៅក្នុងទម្រង់ ឯកបទមុរតិ ទ្រង់បានបង្ហាញជាមួយនឹងរូបតំណាងនៃអាទិទេពព្រះវិស្ណុ និងព្រះព្រហ្ម ដែលរួមគ្នាជាមួយព្រះសិវៈ បង្កើតជាទេពត្រីមុរតិដែលលេចចេញពីចំហៀងចង្កេះឡើងទៅលើ។ ទោះយ៉ាងណា ក្រៅពីការបង្ហាញរូបជើងមួយរបស់ព្រះសិវៈក៏ដោយ ក៏មានចម្លាក់បង្ហាញរូបជើងតែម្ខាងម្នាក់របស់ព្រះសិវៈ ព្រះវិស្ណុ និងព្រះព្រហ្មរួមគ្នាផងដែរ នៅប្រទេសឥណ្ឌា។ ពេលខ្លះនៅឥណ្ឌាមានឆ្លាក់ចេញជើងម្ខាងតូចៗរបស់ព្រះព្រហ្ម និងព្រះវិស្ណុជាប់ជាមួយជើងម្ខាងរបស់ព្រះសិវៈ។ ដែលទម្រង់ឈរជើងមួយនេះមិនឃើញមានបង្ហាញក្នុងសិល្បៈខ្មែរទេ ត្បិតអីយើងឃើញមានឆ្លាក់តែរូបអង្គុយព្រះភ្នែន និងផុសទេពព្រះវិស្ណុ និងព្រះព្រហ្មនៅសង្ខាងចង្កេះប៉ុណ្ណោះ។

រូបឯកបទតំណាងឱ្យអក្ស័សសរនៃសាកលលោក និងបង្ហាញព្រះសិវៈដ៏ខ្ពង់ខ្ពស់បំផុតដែលទ្រង់បង្កើតព្រះវិស្ណុ និងព្រះព្រហ្មនៅអមសង្ខាង។ ព្រះអង្គទ្រង់មានព្រះភក្រ្ត៥ ព្រះហស ១០ និងកាន់ត្រីសូរ និងញញួរតូចនៅក្នុងដៃ និងកាយវិការពីររបស់គាត់ គឺវរទមុទ្រ និងអភ័យមុទ្រ (រូបលេខ៣-៤)។



**រូបលេខ៣៖** រូបឯកបទ ទម្រង់សទាសិវៈ លេចចេញពីសិវៈលិង្គ និងបង្កើតទាំងពីរ



**រូបភាពទី៤៖** រូបមុខលឹង្គជាអ័ក្សសសរភ្លើង ដែលលេចចេញព្រះភក្រ្តសទាសិវៈ នៅប្រាសាទវត្តអង្គខ្នារ កំពង់ធំ (សារមន្ទីរជាតិ)

[២] Donaldson, 1982: 13

នៅក្នុងគម្ពីលីង្គបុរាណ (*Linga Purana*) ពិពណ៌នាអំពីព្រះសិវៈ គឺជា«ព្រះដែលមានជើង១ ដៃ៤និងភ្នែក៣ដែលឈរជើង១ បន្ទាប់ពីបង្កើតព្រះវិស្ណុពីផ្នែកខាងឆ្វេង និងព្រះព្រហ្មពីផ្នែកខាងស្តាំព្រះអង្គ។ ពេលខ្វះបើទោះបីជាចម្លាក់ព្រះសិវៈ ព្រះវិស្ណុ និងព្រះព្រហ្ម បង្ហាញមានជើងរួមគ្នា (ម្ខាងម្នាក់) គឺជាព្រះរូបមានជើង៣ អាចហៅថាត្រិមុរតិផងដែរ(រូបលេខ២៥-៦)។ ប៉ុន្តែពេលខ្វះទៀតចម្លាក់មិនបានបង្ហាញទាំងអស់ក៏ដោយ ក៏គេហៅថាឯកបទត្រីមុរតិ (*Ekapada-Trimurti*) "ព្រះត្រីមុរតិដែលមានជើងមួយ" ផងដែរ។[៣]

ប៉ុន្តែនៅពេលរូបឯកបទ ឈរជើងមួយតែឯង ដែលអមដោយរូបព្រះវិស្ណុ និងព្រះព្រហ្មសង្ខាង ក៏គេហៅថាឯកបទមុរតិ(រូបតំណាងដែលមានជើងតែមួយ)(រូបលេខ២៧)។ ចម្លាក់បែបនេះយើងឃើញមានបង្ហាញតែនៅប្រទេសឥណ្ឌាទេ តែចម្លាក់នៅខ្មែរ គឺបង្ហាញព្រះសិវៈអង្គុយ និងលេចចេញព្រះព្រហ្មនិងព្រះវិស្ណុពាក់កណ្តាលខ្លួនពីចង្កេះរបស់ទ្រង់។ ជាពិសេសចម្លាក់រូបឯកបទដែលព្រះសិវៈអង្គុយព្រះភ្នែនតែអង្គឯង រួចផុសព្រះព្រហ្មនិងព្រះវិស្ណុពាក់ណ្តាលខ្លួន គឺមានបង្ហាញតែនៅប្រាសាទធំកោះកេរ និងមួយទៀតនៅប្រាសាទព្រៃជ្រូក នៅក្នុងសតវត្សទី១០នៃគ.សប៉ុណ្ណោះ។



***រូបលេខ២៥៖*** ចម្លាក់ឯកបទនៅ Tamil Nandu, *ស.វទី៨គ.ស*



***រូបភាពទី៦៖*** គំនូរឯកបទនៅឥណ្ឌា ( www.britishmuseum.org)



***រូបលេខ២៧៖*** ចម្លាក់ឯកបទ នៅOdisha *ស.វទី១០គ.ស* (Donaldson, 1982: 158)

ចម្លាក់រូបផ្សេងមួយទៀត គឺរូបឯកបទ ដែលគេហៅថា *Mahesha-Ekapada* លេចឡើងជារូបចម្លាក់តំបូងនៅឥណ្ឌាខាងត្បូង (*Mahabalipuram*) ក្នុងសតវត្សទី៨នៃគ.ស។ ការបង្ហាញជា

[៣] Donaldson, 1982: 14

រូបជើងម្ខាងដៃ៤ ប៉ុន្តែមានព្រះកេស៩ ដែលរូបឯកបទនេះបង្ហាញទម្រង់ជាសទាសិវៈ។[៧] ចម្លាក់ឯកបទខ្មែរដូចគ្នានឹងរូបនៅប្រទេសឥណ្ឌាខាងត្បូងដែរ គឺចម្លាក់នៅសារមន្ទីរជាតិភ្នំពេញមកពីព្រៃជ្រូក ដែលបង្ហាញព្រះសិវៈអង្គុយ លេចចេញទេពពីរសង្ខាង និងមានព្រះភក្ត្រ៩ ជាទម្រង់ជាសទាសិវៈផងដែរ(រូបលេខ២៨ )។



**រូបភាពទី៨៖** រូបរឿងឯកបទ(*Ekapada*) និងថ្លាក់បញ្ចូលមុខសទាសិវៈ

មកពីព្រៃជ្រូកសតវត្សទី១០-១១នៃគ.ស (ប្រភពៈសារមន្ទីរជាតិភ្នំពេញ)

ចម្លាក់ឯកបទប្រភេទផ្សេង១ទៀត បង្ហាញរូបមានដៃ១៦ ព្រះភ័ក្ត្រច្រើន ដែលដៃទាំងនោះផ្នែកខាងឆ្វេងកាន់កូនដំបង និងអាវុធតំណាងអោយព្រះសិវៈដូចជា ព្រួញ កងចក្រ កូនស្គរ ដុំមូល និងកំពែងត្រីសូរជាដើម និងមានព្រះហស្ថម្ខាងក្នុងកាយវិការវរទមុទ្រ។ នៅដៃស្តាំកាន់កណ្តឹង ដុំផ្កាម អឌ្ឍចន្ទ ថូទឹក ពូថៅ និងព្រះហស្ថម្ខាងទៀតកាយវិការ*Tarjani mudra*។[៨]

សង្ខេបមកចម្លាក់រូបឯកបទ នៅស្រុកខ្មែរមានតំបូង ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៤ នៅស.វទី១០គ.ស ខាងលិចប្រាសាទក្រហម។ ចម្លាក់រូបឯកបទខ្មែរមួយផ្សេងទៀត ដែលមានទម្រង់ឯកក្នុងស្រុកខ្មែរ គឺនៅព្រៃជ្រូកនៅចុងស.វទី១០គ.ស ដែលមានបង្ហាញបញ្ចូលគ្នាជាមួយទេពសទាសិវៈ ព្រះភក្ត្រ៩ និងព្រះហស១០។ ប៉ុន្តែរូបឯកបទ ដែលមាននៅប្រទេសឥណ្ឌាមាន

---

[៧] Srinivasan et al, 1997: 159-160

[៨] Rao, 1993:138

តាំងពីស.វទី៦នៃគ.ស ដែលមានទម្រង់ដំបូងជាបង្គោលសសរភ្លើងជាមួយព្រះភក្ត្រព្រះសិវៈលេចចេញជារូបព្រះសទាសិវៈ។ ប៉ុន្តែនៅប្រទេសខ្មែរ មានទម្រង់ជាបង្គោលសសរភ្លើង និងព្រះភក្ត្រព្រះសិវៈ គឺបង្ហាញក្នុងស.វទី៧នៃគ.ស នៅក្រុមតំបន់ប្រាសាទសំបូរព្រៃគុក។ ចំណែកទម្រង់បង្ហាញរូបឯកបទនេះ គឺមាន៣ទម្រង់នៅប្រទេសឥណ្ឌា ហើយឆ្លាក់ឈរទាំងអស់។ ប៉ុន្តែចម្លាក់នៅខ្មែរបង្ហាញមាន២ទម្រង់ ទី១អង្គុយភ្នែនមានព្រះភក្ត្រ១ ដៃ២ និងទី២អង្គុយភ្នែនមានព្រះភក្ត្រ៥ ដៃ១០ លេចចេញព្រះព្រហ្មនិងព្រះវិស្ណុពីចង្កេះ៕

## ឯកសារយោង


Sharma B.N,
(1976). “*Iconography of Sadasiva*” Abhinav Publications, pp. 1–3.

Srinivasan, Doris Meth,
(1997). *Many Heads, Arms, and Eyes: Origin, Meaning, and Form of Multiplicity in Indian Art*. BRILL. pp. 159–60.

Donaldson, Thomas,
(1982)."Ekapāda Śiva Images in Orissan Art". *Ars Orientalis*. Freer Gallery of Art, The Smithsonian Institution and Department of the History of Art, University of Michigan, pp.13. JSTOR 4629316

Rao, T.A. Gopinatha
(1993). Elements of Hindu iconography, Part II (2 ed.), *Motilal Banarsidass.*


AMS អរិយធម៌ខ្មែរ KHMER CIVILIZATION